# DRAFT សុន្ទរកថា

របស់

ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី

ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្លែងក្នុងឱកាសប្រារព្ធ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ០១ ធ្នូ

"ឆ្ពោះទៅសម្រេចបាននូវគោលដៅបញ្ឈប់ការចម្លងមេរោគអេដស៍ឆ្នាំ២០២៥"

"ឆាប់ធ្វើតេស្តឈាម ឆាប់ព្យាបាល  ឆ្ពោះទៅបញ្ចប់អេដស៍"

នៅ កោះពេជ្រ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៦

- *ឯកឧត្តម លោកជំទាវ ដែលជាតំណាងក្រសួងមន្ទីរនិងស្ថាប័នរដ្ឋ*
- *លោកលោកស្រីដែលជាតំណាងដៃគូអភិវឌ្ឍន៍និងសង្គមស៊ីវិល*
- *លោកលោកស្រីដែលជាតំណាងប្រជាជនប្រឈមមុខខ្ពស់និងតំណាងអ្នករស់នៅជាមួយមេរោគអេដស៍*
- *លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ព្រមទាំងក្មួយៗ សិស្ស និស្សិត ជាទីស្រឡាញ់ !*

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តិយសបំផុត និង មានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និង អន្តរជាតិ   នៅក្នុងឱកាសប្រារព្ធ "ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ០១ ធ្នូ" ឆ្នាំ២០១៦ ដ៏មានអត្ថន័យ និង សារៈសំខាន់  ស្របពេលដែលកិច្ចខិតខំប្រឹងប្រែងប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍ ទទួលបាននូវជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈ តាមរយៈការកាត់បន្ថយការចម្លងមេរោគអេដស៍ថ្មី ការកាត់បន្ថយអត្រាមរណៈភាពដោយសារជំងឺអេដស៍ថ្មី និង ការកាត់បន្ថយអត្រារើសអើង និងមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ និង ជំងឺអេដស៍ថ្មី ។

ឯកឧត្តម លោកជំទាវ លោក-លោកស្រី និងក្មួយៗជាទីរាប់អាន

ថ្ងៃនេះជាថ្ងៃដែលយើងរំលឹកពីការគាំទ្រនិងជួយដល់មនុស្សជាង៧ម៉ឺននាក់ដែលរស់នៅជា មួយមេរោគអេដស៍ហើយក៏គឺជានៅថ្ងៃដែលយើងចងចាំមនុស្សជាង១២ម៉ឺននាក់ដែលបានស្លាប់ដោយមេរោគអេដស៍ផងដែរ។ យើងរំលឹកហើយយើងចងចាំថ្ងៃនេះដោយសារបេសកកម្មរយៈកាល២៥ឆ្នាំកន្លងទៅនេះមិនទាន់បញ្ចប់នៅឡើយទេ។ទោះបីជា យើងបានចលនាធនធានប្រមាណ៧០០លានដុល្លារដើម្បី បានបញ្ចៀសមនុស្សរាប់សែននាក់ឱ្យផុតពីការឆ្លងមេរោគអេដស៍ និង ការបង្កើនអាយុកាលដល់ប្រជាពលរដ្ឋកម្ពុជារាប់ម៉ឺននាក់ដែលកំពុងតែរស់នៅជាមួយមេរោគអេដស៍ និងបានលើកស្ទួយគុណភាព ជីវិតគ្រួសារ ដែលទទួលរងនូវផលប៉ះពាល់នៃមេរោគអេដស៍យ៉ាងណាក៏ដោយក៏យើងនៅមានករណីឆ្លងថ្មីប្រមាណ៦០០ទៅ៧០០នាក់ដែរក្នុងឆ្នាំ២០១៦នេះ។លើសពីនេះទៅទៀត យើងមិនទាន់អាចស្វែងរកឱ្យឃើញអ្នកផ្ទុកមេរោគអេដស៍មួយម៉ឺនប្រាំពាន់នាក់ ដើម្បីឱ្យបានចាប់ផ្តើមព្យាបាលក្នុងប្រព័ន្ធសុខាភិបាលនៅឡើយទេ។ប៉ុន្តែ ប្រទេសកម្ពុជាយើងបានប្តេជ្ញាថាយើងនឹងសម្រេចបាននូវគោលដៅលុបបំបាត់ជំងឺអេដស៍ នៅក្នុងរយៈពេល១០ឆ្នាំ ខាងមុខនេះ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមរំលឹកថា ឆ្នាំនេះយើងប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺ អេដស៍ក្នុងបំណងលើកកម្ពស់ការប្តេជ្ញាចិត្តឆ្ពោះទៅសម្រេចបាននូវគោលដៅ បញ្ឈប់ការចម្លងមេរោគអេដស៍ឆ្នាំ២០២៥ ក្រោមពាក្យស្លោកថា៖ ***ឆាប់ធ្វើតេស្តឈាម ឆាប់ព្យាបាល ឆ្ពោះទៅបញ្ចប់អេដស៍។***ពាក្យស្លោកនេះយើងបានប្រកាសនៅក្នុងឱកាសប្រារព្ធ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ០១ ធ្នូនៅសាលសន្និសីទចតុមុខនាព្រឹកមិញនេះ។

ឯកឧត្តម លោកជំទាវ លោក-លោកស្រី និងក្មួយៗជាទីរាប់អាន

របៀបវារៈនៃការប្រយុទ្ធនឹងជំងឺអេដស៍ មានការវិវឌ្ឍន៍ជាលំដាប់ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។ ទស្សវត្សទីមួយគឺជាពេលដែលយើងពង្រីកអន្តរាគមន៍បង្ការការចំលងមេរោគអេដស៍និងទស្សវត្សទីពីរគឺជាទស្សវត្សដែលយើងគ្រប់គ្រងជំងឺអេដស៍ដោយយើងធ្វើការងារខាងបង្ការការចំលងមេរោគអេដស៍ និងខាងថែទាំព្យាបាលជំងឺអេដស៍ផង។ បច្ចុប្បន្ននេះជាទស្សវត្សទី៣ដែលយើងឈានទៅបញ្ចប់ អេដស៍អោយបានមុនដំណាច់ឆ្នាំ២០២៥ខាងមុខ ។ដំណាក់កាលនេះមិន

មែនជាដំណាក់កាលងាយស្រួលនោះទេ ពិសេសក្នុងបរិបទថ្មីមួយដែលក្នុងនោះយើងត្រូវធានាអោយមានការបន្តវិនិយោគដោយមានការថយចុះធនធានខាងក្រៅនិងការបង្កើនប្រភពធនធានជាតិ។

ក្នុងបរិបទថ្មីនេះខ្ញុំសូមធ្វើការគូសបញ្ជាក់ថាយើងអាចសំរេចគោលដៅវិមហិច្ឆិតាយើងបានដរាបណា **យើងរក្សាពាក្យសន្យា** ដើម្បីធានាថាអ្នកផ្ទុកមេរោគអេដស៍ទាំអស់ទទួលបានសេវាថែទាំនិងការព្យាបាលជំងឺអេដស៍និងធានាថាការចម្លងមេរោគអេដស៍ថ្មីមានតិចជាង៣០០ករណីក្នុងមួយឆ្នាំមុនដំណាច់ឆ្នាំ២០២៥។

ក្នុងឧកាសដ៏វិសេសថ្ងៃថ្លានេះខ្ញុំសូមធ្វើការបកស្រាយថាតើការ**រក្សាពាក្យសន្យានោះមានន័យយ៉ាងដូចម្តេច?**

## នៅថ្នាក់អន្តរជាតិនិងថ្នាក់ជាតិត្រូវរក្សាពាក្យសន្យាអំពីអ្វីខ្លះ?

1. ក្រុមប្រទេស G20 ដែលមានសេដ្ឋកិច្ចរីកចំរើនត្រូវរក្សាពាក្យសន្យា ផ្តល់មូលនិធិយ៉ាងពេញលេញ រួមចំណែកក្នុងមូលនិធិសកលប្រយុទ្ធនឹងជំងឺអេដស៍របេងនិងគ្រុនចាញ់និងមូលនិធិរបស់ប្រធានាធិបតីសហរដ្ឋអាមេរិកលើផែនការបន្ទាន់សំរាប់ការឆ្លើយតបនឹងជំងឺ អេដស៍(PEPFAR)។
2. ដៃគូអភិវឌ្ឍន៍និងក្រុមហ៊ុនឱសថត្រូវរក្សាពាក្យសន្យា ដើម្បីបន្តការអនុញ្ញាតអោយមានការអនុគ្រោះប្រើប្រាស់កម្មសិទ្ធបញ្ញាក្នុងផលិតឱសថហ្សេណេរីក( generic ART drugs)សម្រាប់ការព្យាបាលអ្នកជំងឺអេដស៍ក្នុងប្រទេសក្រីក្រ។
3. នៅពេលដែលប្រទេសកម្ពុជាយើងត្រូវបានចាត់ជាប្រទេសដែលមានប្រាក់ចំណុលមធ្យមកំរិតទាប( Lower Middle Income Country) យើងត្រូវរក្សាពាក្យសន្យាថានឹងចេញដថិកាបដិភាគអោយបានយ៉ាងតិច២០%នៃថវិកាសរុបសំរាប់ការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ដើម្បីឆក់ឧកាសស្រូបទាញជំនួយពីខាងក្រៅ។
4. នៅរយ:កាល១០ឆ្នាំខាងមុខនេះ យើងរក្សាពាក្យសន្យា ថារួមគ្នា និង ជំនះឲ្យបាននូវរាល់ឧបសគ្គនានា ដែលរារាំងដល់ការធ្វើអន្តរាគមន៍របស់យើង តាំងពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ។ទាំងនេះគឺមានន័យថាយើងមិនអាចបោះបង់អ្នកផ្ទុកមេរោគអេដស៍ទាំងជាង៧ម៉ឺននាក់អោយខ្វះខាតឱសថព្យាបាលបានឡើយ។

5. ស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលត្រូវសន្យាថាពិចារណារួមគ្នារិះរករូបមន្តមួយណាដើម្បីឱ្យសម្រេចបានផលជាអតិបរិមា លើធនធានពីខាងក្រៅដែលមានទំហំកាន់តែស្តួច ស្តើងជាលំដាប់នោះ។
6. យើងរក្សាពាក្យសន្យា ដើម្បីធានាថារៀបចំយន្តការរៀបចំផែនការរយៈកាលវែងនិងពង្រឹងភាពជាម្ចាស់នៃការឆ្លើយតបនឹងមេរោគអេដស៍ប្រកបដោយចីរភាពនៅពេលដែលដៃគូអភិវឌ្ឍន៍បាននិងកំពុងដកជំនួយជាបណ្តើៗ។

ចំណែកឯ**នៅកំរិតស្ថាប័ន អង្គភាពប្រតិបត្តិ និងនៅមូលដ្ឋាន**តើអ្នកណាខ្លះដែលត្រូវរក្សាពាក្យសន្យាហើយត្រូវរក្សាសន្យាអំពីអ្វីដើម្បីរួមចំណែកកសាងមនុស្សជំនាន់ថ្មីមួយដែលគ្មានមេរោគអេដស៍?

1. រដ្ឋអំណាចមូលដ្ឋាននិងនគរបាលត្រូវរក្សាពាក្យសន្យាថានឹងសហការជាមួយបុគ្គលិកសុខាភិបាលនិងតំណាងប្រជាជនគន្លឹះរៀបចំបរិយាកាសគាំទ្រអោយប្រជាជនប្រឈមមុខខ្ពស់មានស្ត្រីក្នុងសេវាកំសាន្តសប្បាយ ក្រុមបុរសរួមភេទជាមួយបុរស អ្នកបំប្លែងភេទនិងអ្នកប្រើប្រាស់គ្រឿងញៀនអាចទទួលបានព័ត៌មាន ស្រោមអនាម័យ និងសេវាថែទំព្យាបាលទាំងឡាយដែលគេត្រូវការ។
2. ត្រូវរក្សាពាក្យសន្យាថាមិនទុកអោយនរណាម្នាក់នៅឯកោនោះការថែទាំនិងព្យាបាលមួយដែលមានគុណភាព បុគ្គលិកសុខាភិបាលធានាថាសេវាទាំងអស់ពុំមានការរើសអើង។មូលនិសមធម៌ផ្នែកសុខាភិបាលត្រូវតែធានាផ្តល់ជូនអ្នកជំងឺអេដស៍ដែលក្រីក្រ។
3. នៅតាមស្រុកប្រតិបត្តិក្រុមឆ្នើមត្រូវពិចារណារួមគ្នាជាមួយរដ្ឋអំណាចមូលដ្ឋាននិងនគរបាលរកអោយឃើញអ្នកផ្ទុកមេរោគអេដស៍នៅក្នុងមូលដ្ឋានខ្លួនដែលមិនទាន់បានធ្វើតេស្តឈាម និងទទួលសេវាថែទាំនិងព្យាបាល។

ចំណែកឯនៅ**កំរិតគ្រួសារនិងកំរិតបុគ្គលតើត្រូវរក្សាពាក្យសន្យា**យ៉ាងដូចម្តេចដើម្បីរួមចំណែកបញ្ចប់អេដស៍នៅឆ្នាំ២០២៥ខាងមុខនេះ?

1. គ្រួសារនិមួយៗរក្សាពាក្យសន្យាថារំលឹកនិងផ្សព្វផ្សាយអោយសមាជិកគ្រួសារទាំងអស់មានការប្រុងប្រយ័ត្នកំរិតខ្ពស់និងជាពិសេសកែប្រែការប្រព្រឹត្តដែលនាំអោយប្រឈមនឹងមេរោគអេដស៍។

2. ប្រជាជនគន្លឹះនិងដៃគូរក្សាពាក្យសន្យាថាប្រើប្រាស់ស្រោមអនាម័យអោយបានទៀងទាត់នៅរាល់ពេលដែលរួមភេទ។អ្នកប្រើប្រាស់គ្រឿងញៀនរក្សាពាក្យសន្យាថាមិនប្រើប្រាស់ម្ជុលសឺរាំងជាមួយមិត្តភក្តិឡើយ។
3. អ្នកផ្ទុកមេរោគអេដស៍ត្រូវរក្សាពាក្យសន្យាថានឹងលេបថ្នាំអោយបានទៀងទាត់តាមវេជ្ជបញ្ជានិងជាពិសេសមិនចំលងមេរោគអេដស៍ទៅអ្នកដទៃឡើយ។
4. យុវវ័យត្រូវរក្សាពាក្យសន្យាថាមិនបណ្តែតបណ្តោយខ្លួនប្រព្រឹត្តិអ្វីដែលនាំអោយប្រឈមនឹងមេរោគអេដស៍។យុវវ័យត្រូវរក្សាពាក្យសន្យាថាផ្សព្វផ្សាយអោយយុវវ័យណាដែលប្រឈម*ឆាប់ធ្វើតេស្តឈាម និងឆាប់ព្យាបាល អោយទាន់ពេលវេលា។*

ជាសរុបមក **រក្សាពាក្យសន្យា** មានវិសាភាពទូលំទូលាយគ្របដណ្តប់ពីកំរិតពិភពលោកមកដល់កំរិតជាតិរហូតមកដល់កំរិតស្ថាប័ន អង្គភាពប្រតិបត្តិ និងមូលដ្ឋានហើយចុងក្រោយបង្អស់ដល់កំរិតគ្រួសារនិងបុគ្គល។ **រក្សាពាក្យសន្យា**មិនមែនមានន័យត្រឹមតែធនធានថវិកាទេ គឺលាតសន្ធឹងរហូតដល់ការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រ ការពង្រឹងយន្តការ ការគ្រប់គ្រងធនធានមនុស្ស ការប្រើប្រាស់បច្ចេកវិជ្ជានិងយុទ្ធវិធីថ្មីៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់តាំងពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិនិងការធានាអភិបាលកិច្ចល្អផងដែរ។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី និងក្មួយៗជាទីរាប់អាន**

ឆ្លៀតក្នុងឱកាសនេះ តាងនាមប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះ ក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធនិងសង្គមស៊ីវិលតំណាងប្រជាជនគន្លឹះនិងអ្នកផ្ទុកមេរោគអេដស៍ដែលបានខិតខំប្រឹងប្រែងប្រកបដោយការ ប្តេជ្ញាចិត្តខ្ពស់ធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍ ប្រកបដោយជោគជ័យក្នុងស្ថានភាពដ៏លំបាកស្មុគ្រស្មាញ និង មានបញ្ហាប្រឈមជាច្រើន។

ខ្ញុំសង្ឃឹមថាការប្តេជ្ញាចិត្ត រៀបចំអនាគតសម្រាប់អ្នកជំនាន់ក្រោយដែលគ្មានជំងឺអេដស៍ និងការធានាការរស់នៅក្នុងភាពថ្លៃថ្នូរ និង រុងរឿងរបស់ប្រជាជនកម្ពុជាគ្រប់រូប ជាកត្តាជំរុញឱ្យយើង

ម្នាក់ៗ មានភាពអង់អាចក្នុងការរួមចំណែកទទួលយកការងារសង្គមដ៏ថ្លៃថ្លានេះ ជាការទទួលខុសត្រូវរបស់យើងផ្ទាល់ ក្នុងដំណាក់កាលចុងក្រោយនៃការឆ្លើយតបនឹងមេរោគអេដស៍ និង ជំងឺអេដស៍តាមមុខនាទីរបស់យើងម្នាក់ៗ ក្រោមពាក្យស្លោកថា “ **ឆាប់ធ្វើតេស្តឈាម ឆាប់ព្យាបាល ឆ្ពោះទៅបញ្ឈប់អេដស៍** “ ។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធពរជូនអង្គពិធីទាំងមូលនូវពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និង សូមឱ្យសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀតជូនជាតិ មាតុភូមិ សូមប្រកាសជាឱទ្បារិកថា “*ដរាបណាយើងទាំងអស់គ្នារក្សាពាក្យសន្យាហើយប្តេជ្ញាចិត្តបំពេញនាទីរៀងៗខ្លួននោះទើបយើងអាចសម្រេចគោលដៅបញ្ចប់ការចម្លងមេរោគអេដស៍ ឆ្នាំ២០២៥ ខាងមុខនេះបាន” ៕*

សូមអរគុណ!